# សេចក្តីណែនាំ
# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ
# ខែតុលា ឆ្នាំ២០១០

**សេចក្តីផ្តើម**

សេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះត្រូវបានដាក់ឱ្យអនុវត្ត នាឆ្នាំ២០០៧ ដើម្បីពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងបង្កើនប្រសិទ្ធភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ សេចក្តីណែនាំនេះបានផ្តល់ការគាំទ្រខាងផ្នែករចនាសម្ព័ន្ធគ្រប់គ្រង និងវិសាលភាពការងារដល់ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ ។ យោងតាមរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តន៍ការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះកន្លងមក និងស្របតាមវឌ្ឍនភាពខាងគោលនយោបាយដូចមានចែងនៅក្នុង*«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ - បច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣»* ព្រមទាំងកិច្ចការពាក់ព័ន្ធនឹងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនិងវឌ្ឍនភាពក្នុងការដ្ឋានកំណែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាល សេចក្តីណែនាំនេះត្រូវបានកែសម្រួលឡើងវិញ ដើម្បីដោះស្រាយបញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងសមាជិកភាព រចនាសម្ព័ន្ធគ្រប់គ្រង វិសាលភាពការងារ និងលទ្ធផលក្នុងការអនុវត្តន៍ការងារ ។ គោលដៅចម្បងនៃសេចក្តីណែនាំនេះដែលផ្តោតលើការលើកកម្ពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ភាពជាដៃគូនិងប្រសិទ្ធភាពនៃក្រុមការងារបច្ចេកទេសចម្រុះ ពុំមានអ្វីប្រែប្រួលឡើយ ។

សេចក្តីណែនាំថ្មីនេះនឹងផ្តល់ជាមគ្គុទេស្ទក៍គោល សម្រាប់ធានាឱ្យមានសង្គតិភាពរវាងការងារតាមវិស័យ និង*«យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២»*ព្រមទាំងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ។ ក្នុងស្មារតីនេះ សេចក្តីណែនាំថ្មីនេះអាចជួយក្រុមការងារបច្ចេកទេសចម្រុះ ក្នុងការធ្វើអាទិភាវូបនីយកម្មការងារ ក៏ដូចជាការពង្រឹងទំនាក់ទំនងការងាររបស់ខ្លួន ជាមួយនឹងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) ព្រមទាំងផ្តោតសំខាន់ទៅលើការសម្រេចលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ។

ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ គឺជាអង្គភាពសម្រាប់ផ្តល់ការគាំទ្រ និងកិច្ចសម្របសម្រួល ។ ក្រុមការងារបច្ចេកទេសចម្រុះទាំងនេះមិនមែនបង្កើតឡើង ដើម្បីធ្វើការជំនួស ឬមានមុខងារជាន់គ្នាជាមួយនឹងក្រសួងនិងស្ថាប័នសាមីឡើយ ។ ក្រុមការងារបច្ចេកទេសចម្រុះត្រូវមានគណនេយ្យភាពចំពោះក្រសួងនិងស្ថាប័នរបស់ខ្លួន ។ ប្រធានក្រុមការងារបច្ចេកទេសចម្រុះដែលតំណាងឱ្យរាជរដ្ឋាភិបាលនៅក្នុងក្រុមការងារនិមួយៗ ទន្ទឹមនឹងជំរុញឱ្យមានការពិភាក្សា និងការឯកភាពគ្នា ក៏ជាអ្នកមានសិទ្ធិសម្រេចចុងក្រោយលើការងារទាំងឡាយរបស់ក្រុមការងារផងដែរ ។ ក្នុងផ្នែកមួយនៃយន្តការស្តីពីការបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ក្រុមការងារបច្ចេកទេសចម្រុះត្រូវមានកាតព្វកិច្ចរាយការណ៍វឌ្ឍនភាពការងាររបស់ខ្លួន ជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ពិសេសធានាការបន្តអនុវត្តន៍ផែនការតាមវិស័យ កម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល និងកិច្ចប្រឹងប្រែងដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ ម្យ៉ាងវិញទៀត សកម្មភាពការងារដែលពាក់ព័ន្ធនឹងការអនុវត្តន៍សូចនាករតាមដានរួមគ្នាដោយផ្អែកលើ

លទ្ធផល (Result-Based JMIs) ដែលត្រូវបានអនុមតិនៅក្នុង*«វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣»* នាខែមិថុនាឆ្នាំ២០១០ អាចតំរែតម្រង់ការងារភាគច្រើនរបស់ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗផងដែរ ។

សេចក្តីណែនាំនេះមិនមែនមានលក្ខណៈជា«សេចក្តីបង្គាប់» នោះទេ ។ បណ្តាគោលការណ៍ស្តីពីភារកិច្ចនិងរចនាសម្ព័ន្ធដែលមានចែងក្នុងសេចក្តីណែនាំនេះ ពុំមានលក្ខណៈជាការចាប់បង្ខំឡើយ ។ ប៉ុន្តែ វាមានសារៈសំខាន់ដល់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណត់អាទិភាព និងរៀបចំសកម្មភាពរបស់ខ្លួន ដោយផ្អែកតាមតម្រូវការជាក់ស្តែង លទ្ធភាពខាងធនធាន និងសមត្ថភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ។ ក្នុងស្មារតីនេះ សេចក្តីណែនាំបានផ្តល់នូវគោលការណ៍និងនីតិវិធី ដើម្បីគាំទ្រដល់កិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះដែលត្រូវឆ្លុះបញ្ចាំងក្នុងលក្ខខ័ណ្ឌយោង (Terms of Reference) និងផែនការសកម្មភាពប្រចាំឆ្នាំ ដោយត្រូវផ្តោតការយកចិត្តទុកដាក់ដល់បណ្តាចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ÷

## សមាសភាពរបស់ក្រុមការងារ

ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗត្រូវមានសមាជិកដែលតំណាងឱ្យរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។ ប្រធានក្រុមការងារបច្ចេកទេសចម្រុះ តាមរយៈការពិភាក្សាជាមួយសមាជិកដែលមានបច្ចុប្បន្នគឺជាអ្នកសម្រេចចុងក្រោយលើសមាជិកភាពរបស់ក្រុមការងារ ។ ទន្ទឹមនឹងនេះ ដើម្បីធានាការពិភាក្សាឱ្យចំទិសដៅក្រុមការងារបច្ចេកទេសចម្រុះនិមួយៗត្រូវយកចិត្តទុកដាក់លើបណ្តាចំណុចដូចខាងក្រោម ÷

១- ប្រធានក្រុមការងារបច្ចេកទេសចម្រុះដែលចាត់តាំងដោយរាជរដ្ឋាភិបាល : ប្រធានក្រុមការងារត្រូវចាត់តាំងដោយប្រធានស្ថាប័ន និងត្រូវបំពេញការងារជាតំណាងឱ្យស្ថាប័នរបស់ខ្លួន ព្រមទាំងមានលទ្ធភាពដោះស្រាយបញ្ហានានារបស់ក្រុមការងារ និងដឹកនាំកិច្ចពិភាក្សាប្រកបដោយភាពរលូន ។ ទន្ទឹមនឹងនេះដែរ ប្រធានក៏ត្រូវមានការប្តេជ្ញាខ្ពស់ និងត្រូវសហការជាមួយក្រសួងនិងស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាល ដែលមានតំណាងរបស់ខ្លួននៅក្នុងក្រុមការងារបច្ចេកទេសចម្រុះ ព្រមទាំងយល់ដឹងអំពីគម្រោងឬកម្មវិធីដែលដៃគូអភិវឌ្ឍន៍កំពុងគាំទ្រដល់វិស័យរបស់ខ្លួន ។

២- តំណាងក្រសួងនិងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលក្នុងក្រុមការងារ : សមាជិកទាំងនេះត្រូវគាំទ្រកិច្ចសម្របសម្រួលអន្តរស្ថាប័នរបស់រាជរដ្ឋាភិបាល (Cross-Government) ពិសេសនៅក្នុងការដ្ឋានកំណែទម្រង់ស្នូលនានា ។ សមាជិកទាំងនេះត្រូវមានសមត្ថភាព និងមានការយល់ដឹងខាងបច្ចេកទេស និងជាមន្ត្រីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់តំណាងឱ្យក្រសួងនិងស្ថាប័ន ។ លើសពីនេះ ក៏មានសិទ្ធិគ្រប់គ្រាន់ក្នុងការលើកទស្សនៈ និងបញ្ចេញមតិក្នុងនាមស្ថាប័នសាមី ហើយមានលទ្ធភាពក្នុងការផ្តល់ព័ត៌មាន ក៏ដូចជាការតាមដានវឌ្ឍនភាពនៃការអនុវត្តន៍សកម្មភាពការងារនៅតាមក្រសួង ឬស្ថាប័នរបស់ខ្លួន ។ មន្ត្រីបង្គោលនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.នា) នឹងចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមការងារ សម្រាប់ផ្តល់ការគាំទ្របច្ចេកទេសដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។

៣- ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ក៏ត្រូវតែជាតំណាងជាន់ខ្ពស់របស់ស្ថាប័ន ឬប្រទេសផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ហើយត្រូវមានសមត្ថភាពនិងជំនាញច្បាស់លាស់លើការងាររបស់វិស័យ និងមានឆន្ទៈក្នុងការចែករំលែកព័ត៌មានដល់ដៃគូអភិវឌ្ឍន៍ដទៃទៀត ។ ដៃគូអភិវឌ្ឍន៍ត្រូវជ្រើសតាំងប្រធានសម្របសម្រួល ឬផ្លាស់ប្តូរប្រធានសម្របសម្រួល ។ ប៉ុន្តែ ដើម្បីធានាចីរភាពការងារ ប្រធានសម្របសម្រួលអាចគាំទ្រក្រុមការងារបច្ចេកទេសចម្រុះក្នុងរយៈពេលយ៉ាងតិចពីរឆ្នាំ ។

៤- តំណាងដៃគូអភិវឌ្ឍន៍ដទៃទៀតដែលធ្វើការក្នុងវិស័យនិមួយៗគួរមានឋានានុក្រម និងសមត្ថភាពសមស្រប ព្រមទាំងអាចចែករំលែកព័ត៌មាន និងគាំទ្រដល់ប្រធានក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ។ (ដៃគូអភិវឌ្ឍន៍អាចសម្របសម្រួល និងឯកភាពគ្នាជាមុន ដោយមិនចាំបាច់ឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ដែលគាំទ្រវិស័យនិមួយៗ ចូលរួមក្នុងក្រុមការងារបច្ចេកទេសចម្រុះនោះឡើយ) ។

៥- ចំពោះលេខាធិការដ្ឋាន ក្រសួងឬស្ថាប័នសាមីអាចបង្កើតលេខាធិការដ្ឋានមួយ ដែលឋិតក្រោមការដឹកនាំរបស់ប្រធានក្រុមការងារ ដើម្បីជួយសម្រួលកិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះ និងដើម្បីធ្វើការជាមួយបណ្តាដៃគូអភិវឌ្ឍន៍ ព្រមទាំងជាតំណាងឱ្យក្រុមការងារបច្ចេកទេសចម្រុះនោះនៅក្នុងក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូនិងសុខដុមនីយកម្ម ។

៦- មន្ត្រីបង្គោលសម្រាប់ការងារអន្តរវិស័យ ឧទាហរណ៍ការបញ្ជ្រាបយេនឌ័រ បរិស្ថាននិងបម្រែបម្រួលអាកាសធាតុនៅតាមក្រសួងឬស្ថាប័ននិមួយៗរបស់រាជរដ្ឋាភិបាល ប្រសិនបើចាំបាច់ ។

៧- ទីប្រឹក្សាបច្ចេកទេសដែលបំពេញការងារផ្ទាល់ក្នុងគម្រោងឬកម្មវិធីនៅតាមក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាល អាចចូលរួមកិច្ចប្រជុំរបស់ក្រុមការងារក្នុងឋានៈជាអ្នកជំនាញការ ហើយក៏ជាប្រភពសំខាន់សម្រាប់អភិវឌ្ឍសមត្ថភាពផងដែរ ។ ប៉ុន្តែ ទីប្រឹក្សាទាំងនេះមិនអាចបំពេញតួនាទីជាប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍បានឡើយ ។

៨- ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗអាចអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលឱ្យចូលរួមក្នុងក្រុមការងារបច្ចេកទេសចម្រុះ ។ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងនោះត្រូវមានតួនាទីប្រតិបត្តិការច្បាស់លាស់ ឬបានផ្តល់ការគាំទ្រនិងសេវានៅក្នុងវិស័យដែលពាក់ព័ន្ធនឹងក្រុមការងារបច្ចេកទេសចម្រុះ ។ លើសពីនេះ ក៏ត្រូវមានសមត្ថភាពនិងការប្តេជ្ញា សម្រាប់ធ្វើជាតំណាងឱ្យសង្គមស៊ីវិលទាំងមូល ហើយក៏ត្រូវផ្តល់ព័ត៌មានស្តីពីគម្រោងដែលកំពុងអនុវត្ត (តាមរយៈប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាលរបស់ ក.អ.ក/គ.ជ.នា) ។

## <u>ទំហំរបស់ក្រុមការងារបច្ចេកទេសចម្រុះ</u>

ក្រុមការងារបច្ចេកទេសចម្រុះត្រូវមានទំហំសមរម្យ ដើម្បីធានាឱ្យមានតុល្យភាពក្នុងភាពជាតំណាងរបស់ភាគីពាក់ព័ន្ធ និងប្រសិទ្ធភាពនៃការពិភាក្សា ។ ដូចនេះ ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗត្រូវអនុវត្តដោយផ្អែកតាមគោលការណ៍ដូចខាងក្រោម ÷

១- ប្រធានក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ តាមរយៈការពិភាក្សាជាមួយសមាជិករបស់ខ្លួន ត្រូវកំណត់ចំនួនសមាជិកកម្រិតអតិប្បរមា ។

២- ក្នុងករណីចាំបាច់តម្រូវឱ្យមានសមាជិកច្រើន ក្រុមការងារបច្ចេកទេសចម្រុះអាចបង្កើត *«ក្រុមស្នូល»* ដែលអាចជួបប្រជុំទៀងទាត់ ហើយត្រូវរាយការណ៍អំពីលទ្ធផលការងារនៅកិច្ចប្រជុំពេញអង្គរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ទន្ទឹមនឹងនេះ ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងក្រុមស្នូល ក៏អាចចែករំលែកព័ត៌មានស្តីពីវឌ្ឍនភាពការងារដល់ដៃគូអភិវឌ្ឍន៍ដទៃទៀតផងដែរ ។

៣-«អនុក្រុមការងារ» អាចបង្កើតបាននៅតាមក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ (ដូចដែលកំពុងអនុវត្តតាមក្រុមការងារមួយចំនួន) សម្រាប់ដោះស្រាយបញ្ហាលំអិត តាមកាលបរិច្ឆេទកំណត់ ឬជាប្រចាំ ។

## <u>បញ្ហាអន្តរវិស័យ និងកិច្ចសម្របសម្រួលអន្តរក្រសួង</u>

ក្រុមការងារបច្ចេកទេសចម្រុះត្រូវមានប្រធានបទជាក់លាក់ដែលពាក់ព័ន្ធនឹងវិស័យ ឬកំណែទម្រង់ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗអាចបង្កើតអនុក្រុមការងារដើម្បីដោះស្រាយបញ្ហាអន្តរវិស័យ ។ ទន្ទឹមនឹងនេះ ក្រុមការងារគួរចាត់តាំងមន្ត្រីបង្គោលរបស់ខ្លួន សម្រាប់ដោះស្រាយបញ្ហាអន្តរវិស័យដែលពាក់ព័ន្ធនឹងក្រុមការងាររបស់ខ្លួន ។

លើសពីនេះ គួររៀបចំឱ្យមានកិច្ចប្រជុំរបស់សមាជិកស្នូលនៃបណ្តាក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធដើម្បីធានាឱ្យមានសង្គតិភាពក្នុងជំហររបស់រាជរដ្ឋាភិបាលនៅតាមក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់អនុវត្តសកម្មភាព និងតាមដាន ។ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នឹងផ្តល់កាលានុវត្តភាពបន្ថែម សម្រាប់ពិនិត្យលើទំនាក់ទំនងអន្តរវិស័យ និងបញ្ហាប្រឈម ដែលក្រុមការងារបច្ចេកទេសចម្រុះត្រូវរាយការណ៍កិច្ចការទាំងអស់នេះ ជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

## <u>លក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតក្រុមការងារបច្ចេកទេសចម្រុះ</u>

ការបង្កើតក្រុមការងារបច្ចេកទេសចម្រុះគួរអនុវត្តតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ដូចខាងក្រោម ÷

១- ក្រុមការងារបច្ចេកទេសចម្រុះត្រូវកំណត់ប្រធានបទ ឬវិស័យទទួលខុសត្រូវឱ្យច្បាស់លាស់ ។ លើសពីនេះ ក្នុងករណីចាំបាច់ ក៏អាចបង្កើតអនុក្រុមការងារ សម្រាប់ដោះស្រាយបញ្ហាដែលអាចកើតឡើងតាមសមាសភាគនិមួយៗនៃប្រធានបទ ឬនៃវិស័យ ។

២- ក្រុមការងារបច្ចេកទេសចម្រុះត្រូវកំណត់គោលដៅច្បាស់លាស់ ដែលត្រូវអនុវត្តឱ្យបានសម្រេចតាមរយៈការងារផ្ទាល់របស់ខ្លួន ។

៣- ប្រធានបទ ឬវិស័យដែលក្រុមការងារបច្ចេកទេសចម្រុះទទួលខុសត្រូវ មិនគួរទូលំទូលាយពេកទេ ព្រោះអាចបង្កើតការលំបាកក្នុងការកំណត់ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ឬក្នុងតាមដានអំពីវឌ្ឍនភាពនៅតាមបណ្តាក្រសួងឬស្ថាប័នពាក់ព័ន្ធ (បញ្ហាអន្តរវិស័យនានាគួរបញ្ជ្រាបនៅតាមវិស័យ និងក្រុមការងារបច្ចេកទេសចម្រុះទាំងអស់) ។

៤- ក្នុងករណីដែលមានយន្តការសម្របសម្រួល និងចែករំលែកព័ត៌មានរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍រួចហើយ នោះមិនគួរបង្កើតយន្តការស្រប ឬយន្តការបន្ថែមទៀតឡើយ ។

គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គឺជាវេទិកាសមស្របសម្រាប់ពិភាក្សាលើសំណើសុំបង្កើតក្រុមការងារបច្ចេកទេសចម្រុះថ្មី ឬសម្រាប់រៀបចំឡើងវិញនូវយន្តការការងាររវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ គោលដៅចម្បងនៃការពិនិត្យយន្តការឡើងវិញ គឺការសម្រេចឱ្យបានលទ្ធផលខ្ពស់ក្នុងការងារ ។

## **តួនាទី និងភារៈកិច្ចនៃក្រុមការងារបច្ចេកទេសចម្រុះ**

តួនាទីនិងភារៈកិច្ចនៃក្រុមការងារបច្ចេកទេសចម្រុះត្រូវកំណត់ច្បាស់ក្នុងលក្ខខ័ណ្ឌយោង ហើយសកម្មភាពទាំងអស់ត្រូវបានបញ្ចូលក្នុងផែនការការងារប្រចាំឆ្នាំរបស់ក្រុមការងារ ។ សកម្មភាពអាទិភាពទាំងអស់ត្រូវរំលេចក្នុងសូចនាករតាមដានរួមគ្នារបស់ក្រុមការងារ ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់ដល់គោលការណ៍មួយចំនួនផងដែរ ដូចមានចែងខាងក្រោម ÷

*ការផ្សាភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ)*

១- កំណត់អាទិភាពនានាតាមវិស័យ និងរៀបចំយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹង*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣* សម្រាប់អនុវត្ត ។

២- កំណត់បញ្ហាអន្តរវិស័យនានា ដូចជាការបញ្ជ្រាបយេនឌ័រ បរិស្ថាន និងបំរែបំរួលអាកាសធាតុ ដែលក្រុមការងារបច្ចេកទេសចម្រុះអាចផ្តល់ការគាំទ្រ តាមរយៈសកម្មភាពនៅក្នុងវិស័យ ឬតាមរយៈកិច្ចសហការជាមួយក្រសួងឬស្ថាប័នរបស់រាជរដ្ឋាភិបាល ឬក្រុមការងារបច្ចេកទេសចម្រុះដទៃទៀត ។

៣- កំណត់ទិន្នន័យសម្រាប់តាមដានការអនុវត្តន៍ ផ.យ.អ.ជ និងកំណត់ការសិក្សាវិភាគដទៃទៀត ដែលក្រុមការងារបច្ចេកទេសចម្រុះអាចជួយពង្រឹងដល់ការតាមដាន និងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ ផ.យ.អ.ជ ។

៤- ផ្អែកលើការវាយតម្លៃរបស់រាជរដ្ឋាភិបាលលើហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រូវជម្រុញឱ្យមានការតម្រឹមហិរញ្ញប្បទានជាមួយនឹងយុទ្ធសាស្ត្រ និងអាទិភាពជាតិ ។

*យុទ្ធសាស្ត្រតាមវិស័យ*

៥- គាំទ្រការរៀបចំយុទ្ធសាស្ត្រ ឬកម្មវិធីតាមវិស័យ ដើម្បីជម្រុញការអនុវត្តន៍ឱ្យបានសម្រេចនូវបណ្តាគោលដៅនៃ ផ.យ.អ.ជ- បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ (រួមមានបញ្ហាអន្តរវិស័យ) ។ ទន្ទឹមនេះផ្តល់ការគាំទ្រដល់កិច្ចការប្រចាំថ្ងៃរបស់វិស័យ ដោយយកចិត្តទុកដាក់ដល់តម្រូវការក្នុងការពង្រឹងសមត្ថភាពផងដែរ (រួមទាំងពង្រឹងប្រព័ន្ធជាតិ) ។

៦- ផ្តល់ការគាំទ្រតាមទម្រង់ការសមស្រប សម្រាប់រៀបចំ និងអនុវត្តយុទ្ធសាស្ត្រតាមវិស័យ ព្រមទាំងការធ្វើហិរញ្ញប្បទាន ការតាមដាននិងការវាយតម្លៃ ។

៧- អនុវត្ត និងតាមដានការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលបានអនុម័តនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ នាខែមិថុនា ឆ្នាំ២០១០ ហើយដែលផ្សាភ្ជាប់ទៅនឹងគោលដៅនានារបស់ ផ.យ.អ.ជ ។

*ការផ្តល់ហិរញ្ញប្បទាន*

៨- ផ្អែកតាមប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជារបស់ ក.អ.ក/គ.ជ.នា ក្រុមការងារបច្ចេកទេសចម្រុះត្រូវកត់ត្រាបណ្តាគម្រោងកំពុងអនុវត្តទាំងអស់ ដែលដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទាន ហើយដែលឋិតក្នុងរង្វង់សមត្ថកិច្ចរបស់ក្រុមការងាររបស់ខ្លួន (ទោះបីគម្រោងទាំងនោះត្រូវអនុវត្តដោយស្ថាប័ននៃរាជរដ្ឋាភិបាល ឬដោយស្ថាប័នផ្សេងៗទៀតក៏ដោយ) ។

៩- កំណត់គម្រោងត្រៀមអនុវត្តនានា និងហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីឆ្លើយតបនឹងសកម្មភាពអាទិភាពដែលមានចែងក្នុងផែនការ ឬយុទ្ធសាស្ត្រតាមវិស័យ ។

១០- ប៉ាន់ស្មានតម្រូវការហិរញ្ញប្បទានសម្រាប់សកម្មភាពអាទិភាព និងកំណត់ប្រភពហិរញ្ញប្បទានដែលមានស្រាប់ និងធនធានដែលត្រូវកៀរគរបន្ថែម ដោយសហការជាមួយ ក.អ.ក/គ.ជ.នា ដែលជាស្ថាប័នប្រមូលផ្តុំរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ។

១១- គាំទ្រដល់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ដោយធ្វើបច្ចុប្បន្នភាពជាប្រចាំនូវបណ្តាគម្រោង និងកម្មវិធីទាំងអស់ដែលមានក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា របស់ ក.អ.ក/គ.ជ.នា ។ ព័ត៌មានទាំងឡាយស្តីពីគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល ក៏ត្រូវបញ្ចូលក្នុងប្រព័ន្ធទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាលរបស់ ក.អ.ក/គ.ជ.នា ផងដែរ ។

១២- ពិភាក្សាផែនការយុទ្ធសាស្ត្រថវិកាតាមវិស័យ (BSP) ឬក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំកម្មវិធីនីយកម្មសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្រ និងសម្រាប់អនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ។

១៣- ត្រូវមានធនធានគ្រប់គ្រាន់ សម្រាប់ធានាដល់សកម្មភាពនានាដែលពាក់ព័ន្ធនឹងការងារ និងកិច្ចប្រតិបត្តិការរបស់ក្រុមការងារបច្ចេកទេស ពិសេសសម្រាប់អនុវត្តសូចនាករតាមដានរួមគ្នា ។

*ការអភិវឌ្ឍន៍សមត្ថភាព*

១៤- ការអភិវឌ្ឍន៍សមត្ថភាពត្រូវបានចាត់ទុកថាជាផ្នែកមួយនៃកំណែទម្រង់វិស័យសាធារណៈរបស់រាជរដ្ឋាភិបាល ÷

ក- កសាងយុទ្ធសាស្ត្រប្រកបដោយសង្គតិភាពសម្រាប់អភិវឌ្ឍសមត្ថភាព ដោយផ្អែកតាមតម្រូវការ និងភាពចាំបាច់ក្នុងការបំពេញភារកិច្ច ព្រមទាំងយកចិត្តទុកដាក់ដល់ការកសាងសមត្ថភាពខាងស្ថាប័ន រចនាសម្ព័ន្ធ និងមន្ត្រីម្នាក់ៗផងដែរ ។

ខ- កំណត់ និងឯកភាពលើការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស (TA) ក្នុងកម្មវិធី ឬគម្រោង ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នរាជរដ្ឋាភិបាល នៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍន៍សមត្ថភាពតាមវិស័យ ។

គ- រៀបចំសូចនាករនិងតាមដានការអនុវត្តន៍ដើម្បីវាយតម្លៃវឌ្ឍនភាពនៃការអភិវឌ្ឍន៍សមត្ថភាព ។

*ភាពជាដៃគូ និងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ*

១៥- មន្ត្រីនៃ ក.អ.ក/គ.ជ.នា នឹងផ្តល់ការគាំទ្របច្ចេកទេសខាងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការដល់ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ។ ក្នុងក្របខ័ណ្ឌនៃផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងសូចនាករតាមដានរួមគ្នាស្តីពីអាទិភាពប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ក្រុមការងារបច្ចេកទេសចម្រុះត្រូវកំណត់សកម្មភាពនានាដែលពាក់ព័ន្ធនឹងលើកកម្ពស់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងពង្រឹងភាពជាដៃគូ ដែលរួមមានចំណុចសំខាន់ៗដូចខាងក្រោម ÷

ក- ជម្រុញការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី (PBA) សម្រាប់ណែនាំគម្រោងអភិវឌ្ឍន៍/កម្មវិធីគាំទ្រនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រតាមវិស័យ និងសម្រាប់សម្របសម្រួលកិច្ចប្រឹងប្រែងក្នុងការកៀរគរធនធាន ។

ខ- ដឹកនាំកិច្ចពិភាក្សាស្តីពីទម្រង់ការនៃការផ្តល់ហិរញ្ញប្បទាន (Aid Modalities) និងរៀបចំយន្តការភាពជាដៃគូតាមវិស័យនិមួយៗរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ទន្ទឹមនេះ ក៏ត្រូវកំណត់កាលានុវត្តភាពដើម្បីស្វែងរកទម្រង់ការសម្រាប់ធ្វើការងារជាមួយគ្នា និងកំណត់ទម្រង់ការនៃការផ្តល់ហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាព ដែលក្នុងនោះរួមមានអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ការធ្វើប្រតិភូកម្មភាពជាដៃគូ (Delegated Partnerships) កញ្ចប់មូលនិធិ (Basket Funding) ក៏ដូចជាខិតខំប្រឹងប្រែងផ្សេងៗទៀត ដើម្បីលើកកម្ពស់និងពង្រឹងជវភាពនៃភាពជាដៃគូរវាងសមាជិកទាំងអស់របស់ក្រុមការងារ ។

គ- សម្របសម្រួល និងធ្វើសនិទានកម្មនៃការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេស សម្រាប់វាយតម្លៃសមត្ថភាពរួមគ្នា និងយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងកំណែទម្រង់សំខាន់ៗ ដែលអាចជួយពង្រឹង និងប្រើប្រាស់ប្រព័ន្ធជាតិ (សូមមើលការអភិវឌ្ឍន៍សមត្ថភាពខាងលើ) ។

ឃ- ពិនិត្យការប្រើប្រាស់ និងការធ្វើសមាហរណកម្មអង្គភាពអនុវត្តន៍គម្រោង (PIU) ។ ក្នុងបរិបទនៃការអភិវឌ្ឍន៍សមត្ថភាព ក៏ត្រូវពិនិត្យនិងឯកភាពអំពីជំហាននានា ដើម្បីពង្រឹងសមត្ថភាពរបស់ស្ថាប័ននៃរាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ តាមរយៈការធ្វើផែនការធនធាន ការអនុវត្តន៍ និងការរៀបចំរបាយការណ៍ ព្រមទាំងប្រើប្រាស់អង្គភាពអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព ។

ង- តាមដានធនធានដែលបានសន្យា ឬដែលបានព្យាករណ៍ និងធនធានដែលបានប្រើប្រាស់ជាក់ស្តែង (កត់ត្រាក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ) ទើបអាចធានាបានការអនុវត្តន៍សកម្មភាពប្រកបដោយភាពរលូន ។

ច- តាមដានចំនួនបេសកកម្មនិងគាំទ្រដល់ការសិក្សារួមគ្នារបស់ដៃគូអភិវឌ្ឍន៍ ដើម្បីជម្រុញការអនុវត្តន៍ផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ឱ្យពេញលេញតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

ឆ- ជម្រុញការអនុវត្តន៍គោលការណ៍នៃសេចក្តីណែនាំស្តីពីកិច្ចប្រតិបត្តិការសម្រាប់ហិរញ្ញប្បទានឥតសំណង (National Operational Guidelines) និងនីតិវិធីរួមសម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានសប្រតិបត្តិការពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី (Standard Operating Procedures) សម្រាប់កម្ពុ ។

*ការធ្វើរបាយការណ៍ និងការតាមដាន*

១៦- ផ្តល់របាយការណ៍ជាប្រចាំជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ការអនុវត្តន៍សូចនាករតាមដានរួមគ្នា (រួមទាំងអាទិភាពស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ) និងបញ្ហាចាំបាច់ដែលក្រុមការងារបច្ចេកទេសចម្រុះមានបំណងស្នើពិភាក្សាក្នុងកិច្ចប្រជុំរបស់គណៈ-កម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

១៧- រៀបចំ និងឯកភាពអំពីទម្រង់ការសម្រាប់តាមដានរួមគ្នាស្តីពីវឌ្ឍនភាពការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ និងការងាររបស់វិស័យនិមួយៗ ។

១៨- រៀបចំ និងឯកភាពអំពីយន្តការ ដើម្បីផ្តល់ធាតុចូលសម្រាប់រៀបចំរបាយការណ៍វាយតម្លៃប្រចាំឆ្នាំ ឬពាក់កណ្តាលអាណត្តិស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

១៩- ចាត់វិធានការសមស្របសម្រាប់អនុវត្ត និងដោះស្រាយបញ្ហាដែលបានឯកភាពនៅក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក៏ដូចជាក្នុងវេទិកាកិច្ចសហ-ប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ។ ទន្ទឹមនេះ ក៏ត្រូវលើកបញ្ហានានាដែលក្រុមការងារបច្ចេកទេសចម្រុះមានបំណងស្នើពិភាក្សាក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ។

## ដំណើរការនៃកិច្ចប្រជុំ

ក្នុងកិច្ចដំណើរការរបស់ខ្លួន ក្រុមការងារបច្ចេកទេសចម្រុះគួរយកចិត្តទុកដាក់លើចំណុចដូចខាងក្រោម÷

១- ក្រុមការងារបច្ចេកទេសចម្រុះអាចជួបប្រជុំតាមតម្រូវការចាំបាច់ ។ ទន្ទឹមនឹងនេះ ក៏គួរជួបប្រជុំ ដើម្បីពិភាក្សា និងឯកភាពលើរបាយការណ៍ដែលត្រូវផ្ញើមកលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្រប

សម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (ជាទូទៅ កិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ប្រព្រឹត្តិទៅចំនួន៣ដងក្នុងមួយឆ្នាំ) ។ ក្រុមការងារបច្ចេកទេសចម្រុះគួររៀបចំអង្គវិបស្សនាប្រចាំឆ្នាំ ដើម្បីសិក្សាលើបញ្ហាដែលពាក់ព័ន្ធនឹងភាពជាដៃគូ រួមមានរចនាសម្ព័ន្ធការងារ ការគ្រប់គ្រង និងលទ្ធផលដែលសម្រេចបាន ។

២- កិច្ចប្រជុំនីមួយៗរបស់ក្រុមការងារបច្ចេកទេសចម្រុះត្រូវមានរបៀបវារៈច្បាស់លាស់ ដោយត្រូវមានសំណុំឯកសារចាំបាច់មុនពេលកិច្ចប្រជុំ ។ ផែនការការងារ និងសូចនាករតាមដានរួមគ្នា គឺជាមូលដ្ឋានក្នុងការរៀបចំរបៀបវារៈសម្រាប់កិច្ចប្រជុំនីមួយៗរបស់ក្រុមការងារ ។

៣- សមាជិកទាំងអស់មានកាលានុវត្តភាពសម្រាប់ជម្រាបអំពីវឌ្ឍនភាពសំខាន់ៗជូនអង្គប្រជុំ ។

៤- ការប្រជុំត្រៀមរវាងប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ព្រមទាំងសមាជិកដទៃទៀត ក៏ដូចជាការប្រជុំត្រៀមរវាងបណ្ដាដៃគូអភិវឌ្ឍន៍ អាចជួយឱ្យការពិភាក្សារបស់ក្រុមការងារបានចំគោលដៅ និងមានប្រសិទ្ធភាព ។

៥- បង្កើតលេខាធិការដ្ឋានសម្រាប់ជួយសម្របសម្រួលការងារ ។ លេខាធិការដ្ឋានត្រូវមានធនធានគ្រប់គ្រាន់សម្រាប់បំពេញមុខនាទីរបស់ខ្លួន ។ លេខាធិការដ្ឋានមានភារកិច្ចរក្សាកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមការងារ ចែកផ្សាយឯកសារពាក់ព័ន្ធ រៀបចំសេចក្ដីព្រាងរបាយការណ៍ជូនគណៈ-កម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងជាចំណុចប្រមូលផ្ដុំរបស់ក្រុមការងារក្នុងការសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ដូចមានចែងក្នុងមាត្រា៣៥ (ii) នៃក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងកិច្ចសហប្រត្តិការអភិវឌ្ឍន៍ ។ លើសពីនេះ ក៏ត្រូវចូលរួមប្រជុំរបស់ក្រុមការងារបច្ចេកទេសចម្រុះស្ដីពីភាពជាដៃគូនិងសុខដុមនីយកម្ម បណ្ដាញក្រុមការងារបច្ចេកទេសចម្រុះ និងវគ្គបណ្ដុះបណ្ដាលពាក់ព័ន្ធដទៃទៀត។

៦- ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ឬតំណាង និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ត្រូវមានទំនាក់ទំនងគ្នាជាប្រចាំ ក្នុងចន្លោះកិច្ចប្រជុំនីមួយៗ ដើម្បីសម្រួលការតាមដានក្នុងការអនុវត្តន៍សកម្មភាពដែលបានព្រមព្រៀងគ្នា ។

៧- គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គឺជាវេទិកាសម្រាប់ពិភាក្សាបញ្ហានានាដែលមិនអាចដោះស្រាយក្នុងកម្រិតក្រុមការងារបច្ចេកទេសចម្រុះ ។ ទន្ទឹមនឹងនេះ ក៏ជាវេទិកាសម្រាប់ដោះស្រាយបញ្ហាដែលមានចរិតអន្តរវិស័យផងដែរ ។ បញ្ហាទាំងនេះត្រូវរំលេចនៅក្នុងរបាយការណ៍របស់ក្រុមការងារបច្ចេកទេសចម្រុះ មុនពេលកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ។

## ទំនាក់ទំនងការងារ

សមាជិករបស់ក្រុមការងារបច្ចេកទេសចម្រុះដែលជាតំណាងក្រសួង ឬស្ថាប័ននិមួយៗត្រូវពាំនាំព័ត៌មាន និងការសម្រេចរបស់ក្រុមការងារបច្ចេកទេស និងព័ត៌មានអំពីសកម្មភាពដែលត្រូវអនុវត្តរបស់ក្រុមការងារ ជូនស្ថាប័ន ឬស្ថាប័នសាមី ។ ក្នុងន័យដូចគ្នានេះ ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ក៏ត្រូវផ្ដល់ព័ត៌មានស្ដីពី

គម្រោង ឬកម្មវិធីដែលកំពុងអនុវត្ត ឬដែលគ្រោងផ្តល់ការគាំទ្រ ជូនក្រុមការងារបច្ចេកទេសចម្រុះ ។ លើសពីនេះ ប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ក៏ត្រូវចែករំលែកព័ត៌មានស្តីពីការពិភាក្សា និងការសម្រេចរបស់ក្រុមការងារ ជូនដៃគូអភិវឌ្ឍន៍ដទៃទៀតផងដែរ ។

## រចនាសម្ព័ន្ធគាំទ្រ

រចនាសម្ព័ន្ធគាំទ្រផ្ទៃក្នុងនិងខាងក្រៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ មានដូចខាងក្រោម ÷

១- រចនាសម្ព័ន្ធគាំទ្រផ្ទៃក្នុង : លេខាធិការដ្ឋានដែលត្រូវបង្កើតក្នុងក្រសួង ឬស្ថាប័នរបស់ប្រធានក្រុមការងារ មានភារកិច្ចជួយក្រុមការងារបច្ចេកទេសចម្រុះ ក្នុងការរៀបចំកិច្ចប្រជុំ ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមការងារ ឬអនុក្រុមការងារ ព្រមទាំងទំនាក់ទំនងជាមួយក្រសួងឬស្ថាប័នពាក់ព័ន្ធសម្រាប់តាមដានការអនុវត្តន៍សកម្មភាពដែលបានព្រមព្រៀងគ្នា ។ លេខាធិការដ្ឋានត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពរបស់ក្រុមការងារ ជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក៏ដូចជាលើកបញ្ហាជូនវេទិកានេះ សម្រាប់ពិនិត្យ និងដោះស្រាយ ។ លើសពីនេះ ក៏ត្រូវបំពេញតួនាទីជាចំណុចប្រមូលផ្តុំសម្រាប់សម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ដូចមានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រត្តិការអភិវឌ្ឍន៍ (ដូចបានបញ្ជាក់ក្នុងផ្នែកខាងដើម) ។ ដើម្បីជៀសវាងការបង្កើតរចនាសម្ព័ន្ធថ្មី បន្ថែមលើរចនាសម្ព័ន្ធដែលមានស្រាប់ លេខាធិការដ្ឋានគឺជាផ្នែកមួយនៃក្រសួង ឬស្ថាប័ន ហើយជាចំណុចប្រមូលផ្តុំសម្រាប់ទំនាក់ទំនងរវាងប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងប្រធានសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ក៏ដូចជាសមាជិកដទៃទៀតនៃក្រុមការងារបច្ចេកទេសចម្រុះ ។ ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗត្រូវកៀរគរធនធាន ទាំងក្នុងប្រទេស ទាំងពីដៃគូអភិវឌ្ឍន៍ (អាចជាផ្នែកមួយសម្រាប់ការគាំទ្រការអភិវឌ្ឍន៍សមត្ថភាពរបស់ក្រសួងនិងស្ថាប័ន ឬផ្តល់ការគាំទ្រផ្ទាល់ដល់ក្រុមការងារ) សម្រាប់កិច្ចការរបស់លេខាធិការដ្ឋាន ។

២- រចនាសម្ព័ន្ធគាំទ្រខាងក្រៅ : ក្រុមការងារបច្ចេកទេសចម្រុះខ្លះអាចមានតម្រូវការគាំទ្របច្ចេកទេសពី ក.អ.ក/គ.ជ.នា ដែលជាចំណុចប្រមូលផ្តុំសម្រាប់សម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ និងជាលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ការគាំទ្របច្ចេកទេសនេះត្រូវមានសង្គតិភាពជាមួយនឹងផែនការសកម្មភាពស្តីពីសុខដុមនីសកម្ម ការតម្រឹម និងលទ្ធផល ដែលចែងថា ក.អ.ក/គ.ជ.នា ផ្តល់ការគាំទ្របច្ចេកទេសដល់ក្រសួង ឬស្ថាប័នតាមវិស័យនានា ក្នុងការសម្របសម្រួលនិងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយផ្អែកតាមតម្រូវការ និងតាមការស្នើរបស់ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ។

## ការគាំទ្ររបស់ គ.ជ.នា/ក.អ.ក ដល់ក្រុមការងារបច្ចេកទេសចម្រុះ

ក.អ.ក/គ.ជ.នា អាចផ្តល់ការគាំទ្រដល់ក្រុមការងារបច្ចេកទេសចម្រុះដូចខាងក្រោម ÷

១- មន្ត្រីបង្គោលរបស់ គ.ជ.នា/ក.អ.ក នឹងចូលរួមក្នុងកិច្ចប្រជុំនិមួយៗរបស់ក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីផ្តល់ការគាំទ្រ និងគំនិតយោបល់នានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ តាមតម្រូវការរបស់ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ។

២- បណ្តាញក្រុមការងារបច្ចេកទេសចម្រុះគឺជាវេទិកាសម្រាប់ពិភាក្សា និងផ្តល់ការបណ្តុះបណ្តាលដល់លេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសចម្រុះ ប្រធានក្រុមការងារបច្ចេកទេសចម្រុះ មន្ត្រីបង្គោលរបស់ដៃគូអភិវឌ្ឍន៍ និងតំណាងរបស់អង្គការសង្គមស៊ីវិលមួយរូប ។ លើសពីនេះ លេខាធិការដ្ឋានក្រុមការងារ បន្ទាប់ពីពិភាក្សាជាមួយសមាជិករបស់ក្រុមការងារ អាចស្នើរបៀបវារៈសម្រាប់ពិភាក្សាក្នុងកិច្ចប្រជុំ ឬវគ្គបណ្តុះបណ្តាលនានា ។

៣-«ក្លីនិច» : នេះជាមធ្យោបាយដ៏សំខាន់សម្រាប់ផ្តល់ការគាំទ្រដល់ក្រុមការងារបច្ចេកទេសចម្រុះ តាមរយៈការរៀបចំកិច្ចប្រជុំ ឬវគ្គបណ្តុះបណ្តាល ។ «ក្លីនិច» នេះបានផ្តោតលើការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងបញ្ហានានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។

៤- ចំពោះធនធានសម្រាប់គាំទ្រដល់ការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងករណីដែលក្រុមការងារមិនអាចកៀរគរធនធានគ្រប់គ្រាន់សម្រាប់លេខាធិការដ្ឋានបំពេញការងារ ក.អ.ក/គ.ជ.នា អាចផ្តល់ហិរញ្ញប្បទានគាំទ្រក្នុងកម្រិតអប្បបរមា សម្រាប់ការងារណាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការប៉ុណ្ណោះ ។

---